## ការពន្យល់អំពីការប្រើប្រាស់ឯកសារទូទៅសំរាប់សិក្សាព្រះគម្ពីរ General Bible Study Instructions

**សេចក្តីផ្តើម៖**

អត្ថបទនេះណែនាំអ្នកអោយស្គាល់វិធីសាស្រ្តសាមញ្ញមួយ ដើម្បីសិក្សាបទគម្ពីរណាមួយនៅក្នុងព្រះគម្ពីរ ដោយប្រើតែព្រះគម្ពីរ ក្រដាសមួយសន្លឹក និងប៊ិចមួយដើម (ឬខ្មៅដៃមួយដើម) ប៉ុណ្ណោះ ហើយពន្យល់អ្នកអំពីរបៀបប្រើវិធីសាស្រ្តមួយនេះ។ អ្នកអាចប្រើវិធីសាស្រ្តនេះ ដើម្បីសិក្សាព្រះគម្ពីរដោយខ្លួនឯង ឬជាក្រុមបាន។ វាជាគំនិតល្អ ដែលអ្នក (ឬក្រុម) មិនជ្រើសរើសបទគម្ពីរដោយព្រាវៗនោះទេ ប៉ុន្តែអ្នកមានរចនាសម្ព័ន្ធមួយ ដូចជាការអានបញ្ចប់កណ្ឌមួយនៅក្នុងព្រះគម្ពីរ។ ឧទាហរណ៍ អ្នកសិក្សាអំពីម៉ាកុស ១:១-២០ ហើយបន្ទាប់មកម៉ាកុស ១:២១-៤២ ហើយបន្តបន្ទាប់មកទៀតដូច្នេះ។ ការប្រើវិធីសាស្រ្តសិក្សាព្រះគម្ពីរ ជួយអោយមនុស្សធ្វើការសង្កេតពិនិត្យបានល្អលើបទគម្ពីរ ហើយជួយមនុស្សអោយចូលរួមនៅក្នុងក្រុមមួយ។ មនុស្សគ្រប់គ្នាមានឱកាសមើលឃើញអ្វីដែលព្រះមានបន្ទូលតាមរយៈព្រះគម្ពីរ។

**របៀបវារៈ៖**

បទគម្ពីរ៖ ចូរសរសេរបទគម្ពីរ ដែលអ្នកនឹងអាន។ បន្ទាប់មក អធិស្ឋានសូមអោយព្រះនឹងជួយអ្នកយល់បទគម្ពីរ ហើយអ្វីដែលអ្នករៀនបាន នឹងជួយអ្នកអោយទុកចិត្ត និងស្តាប់បង្គាប់ព្រះ។ ចូរអានបទគម្ពីរ ហើយបំពេញក្នុងក្រដាស។

ក្រដាសនេះមានរូបភាពបួន។


បន្ទាប់ពីរូបភាពនេះ អ្នកគួរតែសរសេរអ្វីដែល «បញ្ចេញពន្លឺ» ពីបទគម្ពីរ អ្វីដែលប៉ះពាល់ចិត្តអ្នក ឬទាក់ទាញចំណាប់អារម្មណ៍របស់អ្នក។


បន្ទាប់ពីរូបភាពនេះ សូមសរសេរអ្វីដែលអ្នកពិបាកយល់នៅក្នុងបទគម្ពីរនេះ ឬសំនួរមួយចេញពីបទគម្ពីរដែលអ្នកចង់សួរ។



បន្ទាប់ពីរូបភាពនេះ សូមសរសេរនូវអ្វីដែលអ្នករៀនអំពីព្រះ ចេញពីបទគម្ពីរនេះ។


បន្ទាប់ពីរូបភាពនេះ សូមសរសេរការអនុវត្តសំរាប់ជីវិតរបស់អ្នក។

អ្នកគួរតែសរសេរអ្វីមួយនៅបន្ទាប់ពីរូបភាពនីមួយៗ។

**កំណត់សំគាល់សំរាប់អ្នកដឹកនាំនៅពេលប្រើវិធីសាស្រ្តនេះនៅក្នុងក្រុមមួយ**

អ្នកដឹកនាំគួរតែផ្តល់ពេលវេលាគ្រប់គ្រាន់សំរាប់សមាជិកម្នាក់ៗ ដើម្បីបញ្ចប់ការអានបទគម្ពីរនិងការសរសេរនៅបន្ទាប់ពីរូបភាពនីមួយៗ។

នៅពេលសមាជិកទាំងអស់បានបញ្ចប់ការអាននិងសរសេរហើយ អ្នកអាចចាប់ផ្តើមការពិភាក្សាក្រុមបាន។ ជាការសំខាន់ដែលការពិភាក្សាក្រុមមិនវង្វេងចេញពីបទគម្ពីរនោះ។ សូមព្យាយាមនៅក្នុងបទគម្ពីរ។ ហើយអ្នកដឹកនាំត្រូវតែជួយក្រុមអោយនៅក្នុងបទគម្ពីរ។

សូមសុំសមាជិកម្នាក់ៗអោយចែកចាយនៅក្នុងក្រុម នូវចំនុចមួយ ដែលពួកគេបានសរសេរនៅបន្ទាប់ពី។ សូមចំណាយពេលខ្លះដើម្បីពិភាក្សាអំពីចំលើយទាំងនេះ។

បន្ទប់មកទៀត ហៅពួកគេអោយចែកចាយអំពីសំនួរមួយ ដែលពួកគេបានសរសេរ។ មិនចាំបាច់ឆ្លើយចំពោះសំនួរទាំងនោះទេ។ គោលបំណងចំបងនៃការសួរសំនួរគឺមិនដើម្បីស្វែងរកចំលើយទេ ប៉ុន្តែដើម្បីជួយអោយពួកគេគិតកាន់តែស៊ីជម្រៅអំពីបទគម្ពីរនោះ។ ជាការសំខាន់ដែលអ្នកដឹកនាំមិនព្យាយាមឆ្លើយសំនួរទាំងអស់ ប៉ុន្តែអនុញ្ញាតអោយក្រុមធ្វើការពិភាក្សាវិញ។ នេះមិនមែនជាពេលវេលាសំរាប់គ្រប់គ្នាបង្ហាញចំណេះដឹងខាងព្រះគម្ពីររបស់ខ្លួនទេ។ កុំអនុញ្ញាតអោយនរណាម្នាក់និយាយថា សំនួរនេះមិនល្អទេ។ ប្រសិនបើពួកគេព្យាយាមឆ្លើយ នោះពួកគេត្រូវតែបង្ហាញថា ចំលើយរបស់ពួកគេចេញមកពីព្រះគម្ពីរ (ប្រសើរជាងប្រសិនបើចេញពីបទគម្ពីរដែលអ្នកកំពុងសិក្សា) ហើយចម្លើយរបស់គេមិនគ្រាន់តែជាគំនិតផ្ទាល់ខ្លួន (ឬគំនិតរបស់អ្នកណាទៀត) ដែលមិនចេញពីព្រះគម្ពីរប៉ុណ្ណោះទេ។

បន្ទាប់មកទៀត ហៅពួកគេម្នាក់ៗអោយចែកចាយសេចក្តីពិត*មួយ* ដែលពួកគេបានរៀនអំពីព្រះ។

បន្ទាប់មកទៀត ហៅពួកគេម្នាក់ៗអោយចែកចាយអំពីការអនុវត្ត*មួយ*សំរាប់ជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។

*ការចែកចាយព្រះបន្ទូលរបស់ព្រះ*៖ ដើម្បីចែកចាយព្រះបន្ទូលរបស់ព្រះតាមរយៈវិធីសាស្រ្តនេះ អ្នកអាចសុំអោយសមាជិកម្នាក់ៗជ្រើសរើសចំនុចមួយពីការសិក្សា ដើម្បីចែកចាយជាមួយអ្នកដទៃក្រៅពីក្រុម មុនពេលអ្នកជួបគ្នាម្តងទៀត។

ចុងបញ្ចប់ ក្រុមអាចអធិស្ឋានបញ្ចប់បាន។

## ការសិក្សាលើកក្រោយ៖

ប្រសិនបើអ្នកកំពុងដឹកនាំក្រុមដែលកំពុងសិក្សាព្រះគម្ពីរតាមស៊េរី (ដូចជាការអានតាមកណ្ឌនៅក្នុងព្រះគម្ពីរ) ជាការសំខាន់ដែល ពេលចាប់ផ្តើមការសិក្សា អ្នកសង្ខេបយ៉ាងខ្លីអំពីអ្វីដែលក្រុមបានរៀនបានក្នុងការសិក្សាលើកមុន។ ការនេះអាចចំណាយពេលតិចជាងមួយនាទី មុនពេលអ្នកចាប់ផ្តើមសិក្សាបទគម្ពីរថ្មី។ ក៏ជាការសំខាន់ផងដែរដែលអ្នកពិនិត្យអោយដឹងថា សមាជិកទាំងអស់ពិតជាបានអនុវត្តនៅក្នុងជីវិតនូវអ្វីដែលពួកគេបាននិយាយថា ពួកគេនឹងអនុវត្តនៅក្នុងការសិក្សាលើកមុន។

## សំរាប់មនុស្សដែលមិនចេះអក្សរ

អ្នកអាចយកលំនាំតាមវិធីសាស្រ្តនេះ ដើម្បីសិក្សាជាមួយមនុស្សដែលមិនចេះអក្សរបានផងដែរ។ អ្នកអាចអានព្រះគម្ពីរអោយពួកគេស្តាប់ ហើយពួកគេប្រើនិមិត្តសញ្ញា ដើម្បីចាប់ផ្តើមការពិភាក្សាបាន។